METAFENIX

# ហុងស៊ុយ និងរាសី ប្រចាំឆ្នាំ២០២៦

ពេលវេលាបានបង្ហាញអោយយើងឃើញអំពី

មិត្តល្អ មិត្តសម្លឹងប្រយោជន៍ និងមិត្តដែលជាសត្រូវ

METAFENIX មេតាហ្វីនិច

# មិនមែនយើងមិនដឹងទេ

តែដោយសារនិស្ស័យស្មោះត្រង់របស់យើង

ធ្វើអោយយើងគិតថា

គេដូចយើង គេចោលចរិកឈ្លានពានហើយ

រហូតដល់វេលាមួយ

គេបាញ់សម្លាប់បងប្អូនយើង

ទើបយើងនឹកឃើញប្រវត្តិសាស្ត្រដ៏ឈឺចាប់របស់ខ្លួន

យើងទទូចសុំអោយអន្តរជាតិជួយ

តែគេបានត្រឹមឈរនៅជំហរកណ្តាល រក្សាសុខផ្ទាល់ខ្លួន

យើងក៏ភ្ញាក់រលឹកមួយទៀតថា

METAFENIX មេត្តាហ្វីនិច្ច

នៅក្នុងពិភពលោកនេះ

បើគ្មានប្រយោជន៍ទេ គ្មានអ្នកណានឹងជួយយើងនោះឡើយ

មេត្តាហ្វីនិច្ច

ប្រៀបដូចអំពូលអគ្គិសនីភ្លឺបាន លុះត្រាណាមានចរន្តអគ្គិសនីផ្គត់ផ្គង់ដូច្នោះដែរ

វាគឺជាច្បាប់ធម្មជាតិ ដែលយើងមិនអាចប្រកែកបាន

ឥឡូវនេះដល់ពេលហើយ

ដល់វេលាដែលខ្មែរត្រូវពង្រឹងសមត្ថភាពខ្លួនឯង

METAFENIX
បេក្ខាហ្វីនិច្ច

ដល់វេលាដែលខ្មែរត្រូវរួបរួម
ដើម្បីការពារជាតិមាតុភូមិរបស់ខ្លួន



METAFENIX មេត្តាហ្វីនិច្ច

ប្រជាជនគ្រប់រូប

សុទ្ធតែមានចំណែកកសាងជាតិ

# ការកសាងជាតិបានល្អ

**លុះត្រាយើងម្នាក់ៗកសាងខ្លួនឱ្យក្លាយជាធនធានដ៏រឹងមាំជាមុនសិន**

ការកសាងខ្លួននោះក៏ត្រូវអោយសមស្របនឹង

**កាលៈទេសៈ និងសម័យកាលផងដែរ**

ចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ២៣៖០៥នាទីយប់តទៅ
ថាមពលឆ្នាំភ្លើងយ៉ាងលើមមី ដែលផ្តើមជាមួយវដ្តដៃជីទាំង៦០ថ្មី
នឹងចាប់ផ្តើមមានឥទ្ធិពលខ្លាំងឡើងលើសពីវេលាកាលពីប៉ុន្មានថ្ងៃកន្លងទៅនេះ

វេលានោះ ថាមពលខែជូត និងថាមពលឆ្នាំមមី
នឹងបង្ករជាផលរំខានច្រើនផងដែរ ពិសេសពាក់ព័ន្ធនឹងនយោបាយការបរទេស


METAFENIX
ឆ្នាំថ្មីចាប់ផ្ដើមមានឥទ្ធិពល
ឆ្នាំចាស់អស់ឥទ្ធិពល
ឆ្នាំថ្មីមានឥទ្ធិពលកាន់តែខ្លាំង
ច
កុរ
ជូត
ឆ្លូវ
ខាល
សែននំអី
WINTER SOLISTICS
រដូវរងា
ឆ្នាំចាស់ចាប់ផ្ដើមចុះខ្សោយ
ឆ្នាំថ្មីមានឥទ្ធិពលពេញលេញ

METAFENIX មេត្តាហ្វីនិច្ច

បងប្អូនដែលចេះក្បួនប៉ាជី ប្រហែលជាដឹងហើយថា

មមី ជាវេលាក្តៅបំផុតក្នុងរដូវក្តៅ

METAFENIX មេត្តាហ្វីនិច្ច

ហើយឆ្នាំ២០២៦នេះ ជាវេលា ភ្លើងយ៉ាង លើ មមី
ក្នុងយុគសម័យកាលទី៩ ដែលមានធាតុភ្លើងបន្ថែមទៀត

ដូច្នេះ

រឿងរ៉ាវនានាក្នុងពិភពលោកផុយស្រួយណាស់ក្នុងជំហានថាមពលថ្មីនេះ

ទោះបានដឹងច្បាស់យ៉ាងណាក៏ដោយ

METAFENIX

វាជាថាមពលដែលយើងមិនអាចកែបាន

METAFENIX
មេត្តាហ្វីនិច្ច

អ្វីដែលយើងធ្វើបាន គឺកែថាមពលខ្លួនឯង និងបរិស្ថានដែលយើងរស់នៅ

ព្រមទាំងរៀបចំផែនការយុទ្ធសាស្ត្រ
សម្រាប់ការពារខ្លួន និងសង្គមជាតិអោយមានសុវត្ថិភាព

| កត្តារាសី |
| --- |
| រាសីមេឃ |
| រាសីដី |

ក្នុងកត្តាថាមពលរាសីមេឃ និងរាសីដីរបស់វេលាប្រឈមនិមួយៗ មិនថាដំណើររាសី១០ឆ្នាំ ប្រចាំឆ្នាំ ខែ ថ្ងៃ ឬម៉ោងទេ វាមានវេលាជះឥទ្ធិពលខ្លាំងម្តងម្នាក់ដែល៖

- នៅពាក់កណ្តាលដើមវេលា រាសីមេឃជះឥទ្ធិពលខ្លាំង និងឥទ្ធិពលរាសីដីខ្សោយ
- នៅពាក់កណ្តាលចុងវេលា រាសីដីជះឥទ្ធិពលខ្លាំង និងឥទ្ធិពលរាសីមេឃចុះខ្សោយ

# កត្តាតារាសាស្ត្រ

METAFENIX



9 5 7
8 1 3
4 6 2
S1 S2 S3
SW1 SW2 SW3
W1 W2 W3
NW1 NW2 NW3
N1 N2 N3
NE1 NE2 NE3
E1 E2 E3
SE1 SE2 SE3
丙 Bing
午 Wu
丁 Ding
未 Wei
坤 Kun
申 Shen
庚 Geng
酉 You
辛 Xin
戌 Xu
乾 Qian
亥 Hai
壬 Ren
子 Zi
癸 Gui
丑 Chou
艮 Gen
寅 Yin
甲 Jia
卯 Mao
乙 Yi
辰 Chen
巽 Xun
巳 Si




# ទិសទេវតាប្រចាំឆ្នាំមមី

- ទិសមមី ខាងត្បូង អង្សារ ១៧២.៦ ដល់ ១៨៧.៥

- គប្បីប្រយ័ត្នអោយបានខ្លាំងជៀសវាងការជំស្វាន រុះរើ ជួសជុល មានសម្លេងខ្លាំងៗ ជីកគាស់..
- កុំអង្គុយបែរមុខទៅរកទិសនេះសម្រាប់ធ្វើកិច្ចការសំខាន់ៗ ច្រើនពេក តែល្អសម្រាប់អង្គុយបែរខ្នងទៅរក ព្រោះមាន ទេវតាប្រចាំឆ្នាំនៅជួយការពារពីក្រោយ
- ទិសនេះត្រូវតែស្អាត និងមានអនាម័យ
- សម្រាប់អ្នកកើតឆ្នាំជូត គួរមានរុក្ខជាតិស្រស់ និងក្រឡ អំបិលនៅទិសនេះ ដើម្បីកាត់បន្ថយថាមពលឆុង




# ទិសឆុងពិឃាដទាំងបីប្រចាំឆ្នាំម្សាញ់

- ផ្នែកខាងជើង ចាប់ពីទិសកុរហូតដល់ទិសឆ្លូវ
- ក្នុងចន្លោះអង្សារ ៣២២.៦ ដល់ ៣៧.៥

- គប្បីប្រយ័ត្នអោយបានខ្លាំងជៀសវាងការជំស្វាន រុះរើ ជួសជុល មានសម្លេងខ្លាំងៗ ជីគាស់...
- កុំប្រើទិសនេះសម្រាប់ធ្វើកិច្ចការសំខាន់ៗច្រើនពេក
- ទិសនេះត្រូវតែស្អាត និងមានអនាម័យ
- ដាក់ធុងអំបិលដើម្បីកាត់បន្ថយថាមពលធុង

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

# 1

## ផ្កាយលេខ១ ធាតុទឹក ចូលកណ្តាលទីតាំង

- ទីតាំងកណ្តាលមានធាតុដី
- ឥទ្ធិពលប្រចាំឆ្នាំ៖ បើនិយាយពីឥទ្ធិពលរបស់ផ្កាយ វានាំអោយមានថាមពលល្អសម្រាប់ការបង្កើនកិត្តិនាម ការទទួលស្គាល់សមត្ថភាព ការបង្កើតស្នាដៃថ្មី ការទំនាក់ទំនង កិច្ចការងាររកស៊ី ការវិនិយោគនានា និងការសិក្សាស្រាវជ្រាវ។ តែផ្កាយលេខ១ ជួបផ្កាយលេខ៥(កណ្តាលផ្ទះ) វានឹងបង្ករអោយមានហានិភ័យលើជម្ងឺឆ្លង កាមរោគ និងបញ្ហាត្រចៀកជាដើម។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ គ្រប់គ្នានៅក្នុងផ្ទះ។
- ការណែនាំ៖ ដាក់តាំងលោហៈធាតុ ពិសេសផ្តិលស្ពាន់ ឬវត្ថុមង្គលនានាដែលសាងពីលោហៈនិងតំណាងអោយមានភាពថ្កុំថ្កើង ។
- កត្តាមនុស្ស៖ ប្រើទិសនេះអោយបានច្រើនដើម្បីទទួលឥទ្ធិពលល្អប្រចាំឆ្នាំ មិនគួរគេងនៅទីតាំងនេះទេ។
- ហាមដាក់ទឹកច្រើនជាង២លីត្រ។

METAFENIX

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

# 2

## ផ្កាយលេខ២ ធាតុដី ចូលទិសខាងជើងឆៀងលិច

- ទិសខាងជើងឆៀងលិច អង្សារ ២៩២.៦ ដល់ ៣៣៧.៥
- ធាតុប្រចាំទិស៖ មាស
- ឥទ្ធិពលប្រចាំឆ្នាំ៖ នាំអោយមានភាពជោគជ័យលើហិរញ្ញវត្ថុ និងបង្កើតវឌ្ឍនភាពលើការវិនិយោគពិសេសអចលនទ្រព្យ តែក៏ត្រូវប្រយ័ត្នជម្ងឺពាក់ព័ន្ធនឹងសួត ពោះវៀនធំ ក្បាល និងស្បែកផងដែរ។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ បុរសវ័យចំណាស់ក្នុងគ្រួសារ អ្នកមានផ្កាយជីវិតលេខ៦ អ្នកមានតួច និងកុរ។
- ការណែនាំ៖ គោមអំបិលហិម៉ាល័យ ដាក់តាំងលោហៈធាតុ ពិសេសផ្តិលស្ពាន់ ឬវត្ថុមង្គលនានាដែលសាងពីលោហៈនិងតំណាងអោយមានភាពថ្កុំថ្កើង ។
- កត្តាមនុស្ស៖ ប្រើទិសនេះសម្រាប់កិច្ចការផ្សេងៗអោយបានច្រើនដើម្បីទទួលឥទ្ធិពលល្អប្រចាំឆ្នាំ។

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

# 3

## ផ្កាយលេខ៣ ធាតុឈើ ចូលទិសខាងលិច

- ទិសខាងលិច អង្សារ ២៤៧.៦ ដល់ ២៩២.៥
- ធាតុប្រចាំទិស៖ មាស
- ឥទ្ធិពលប្រចាំឆ្នាំ៖ ជម្លោះទាស់ទែង វិវាទ ភាពតានតឹងផ្លូវច្បាប់ ការនិយាយដើម សម្ពាធផ្លូវចិត្ត ចោរកម្ម និងបញ្ហាសុខភាពពាក់ព័ន្ធនឹងសាច់ដុំ។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ កូនស្រីអាយុតិចជាងគេក្នុងគ្រួសារ អ្នកមានផ្កាយជីវិតលេខ៧ អ្នកមានតួរកា។
- ការណែនាំ៖ ដាក់តាំងភ្លើងក្រហមឬអំពូលអំបិលហិម៉ាល័យ កំរាលព្រំក្រហម និងសម្ភារៈដែលសាងពីដី/សេរ៉ាមិក។ ឃ្លោកដែលមានកាត់មាត់ចំហរគ្រប។
- កត្តាមនុស្ស៖ កុំប្រើប្រាស់ទិសនេះច្រើនពេក។
- ហាម៖ ដំស្វាន រុះរើ ជួសជុល មានសម្លេងខ្លាំងៗ ជីកគាស់..។
- ដាក់ធុងអំបិលដើម្បីកាត់បន្ថយថាមពលធុង។

METAFENIX ប៉េត្តាហ្វីនិច្ស

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

4

## ផ្កាយលេខ៤ ធាតុឈើ ចូលទិសជើងឆៀងកើត

- ទិសខាងជើងឆៀងកើត អង្សារ ២២.៦ ដល់ ៦៧.៥
- ធាតុប្រចាំទិស៖ ដី
- ឥទ្ធិពលប្រចាំឆ្នាំ៖ ល្អសម្រាប់ការពង្រឹងចំណេះដឹង សតិបញ្ញា ស្មារតី ការសិក្សាស្រាវជ្រាវ ប្រជាប្រិយ៍ភាព ទំនាក់ទំនងស្នេហា តែត្រូវរក្សាសុខភាពផ្លូវចិត្តអោយបានល្អ។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ អ្នកមានលេខគ័រជីវិតលេខ៤ មនុស្សប្រុសអាយុតិចជាងគេក្នុងគ្រួសារ អ្នកមានតួខាល និងឆ្លូវ។
- ការណែនាំ៖ តាំងអំពូលភ្លើងក្រហម កម្រាលព្រំក្រហម គ្រឿងបរិក្ខាអគ្គិសនី..។
- កត្តាមនុស្ស៖ ប្រើទិសនេះសម្រាប់កិច្ចការផ្សេងៗអោយបានច្រើនដើម្បីទទួលឥទ្ធិពលល្អប្រចាំឆ្នាំ។

METAFENIX

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

# 5

## ផ្កាយលេខ៥ ធាតុដី ចូលទិសខាងត្បូង

- ទិសខាងត្បូង អង្សារ ១៥៧.៦ ដល់ ២០២.៥
- ធាតុប្រចាំទិស៖ ភ្លើង
- ឥទ្ធិពលប្រចាំឆ្នាំ៖ គ្រោះថ្នាក់ដាច់សាច់ហូរឈាម បំណុល គ្រោះមហន្តរាយ និងការវាយបកតបត។ ទិសនេះនឹងនាំអោយមានអស្ថេរភាពទាំងផ្លូវកាយ និងទាំងផ្លូវចិត្ត។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ អ្នកមានផ្កាយជីវិតលេខ៥ មនុស្សស្រីវ័យកណ្ដាលក្នុងគ្រួសារ និងអ្នកមានតួមមីក្នុងតារាងរាសី។
- ការណែនាំ៖ ដាក់តាំងសម្ភារៈដែលសាងពីលោហៈពិតប្រាកដ លោហៈដែលមានប្រសិទ្ធិភាពខ្ពស់ជាងគេគឺ ស្ពាន់។ វត្ថុតាំងនៅកន្លែងនេះកាន់តែធ្ងន់កាន់តែល្អ។
- កត្តាមនុស្ស៖ កុំប្រើទិសនេះច្រើនពេក។
- ហាម៖ ដាក់ទឹកឬដី វត្ថុមានចលនា ដំស្វាន រុះរើ ជួសជុល សម្លេងខ្លាំងៗ ជីកគាស់..។
- ដាក់ឃ្លោកកាត់មាត់ចំហរ និងក្រឡអំបិលដើម្បីបន្ថយឥទ្ធិពលអាក្រក់។

METAFENIX

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

6

# ផ្កាយលេខ៦ ធាតុមាស ចូលទិសខាងជើង

- ទិសខាងជើង អង្សារ ៣៣៧.៦ ដល់ ២២.៥
- ធាតុប្រចាំទិស៖ ទឹក
- ឥទ្ធិពលប្រចាំឆ្នាំ៖ សិទ្ធិអំណាច ល្បីល្បាញ កេរ្តិ៍ឈ្មោះ និងការងារពាក់ព័ន្ធនឹងនយោបាយ កម្លាំងប្រដាប់អាវុធ តែក៏នឹងនាំអោយមានសម្ពាធអារម្មណ៍ច្រើនណាស់ដែរ។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ អ្នកមានផ្កាយជីវិតលេខ១ មនុស្សប្រុសវ័យកណ្ដាលក្នុងគ្រួសារ និងអ្នកមានតួជូតក្នុងតារាងរាសី។
- ការណែនាំ៖ ដាក់តាំងសម្ភារៈដែលសាងពីលោហៈពិតប្រាកដ លោហៈដែលមានប្រសិទ្ធិភាពខ្ពស់ជាងគេគឺ ស្ពាន់។ វត្ថុតាំងនៅកន្លែងនេះកាន់តែធ្ងន់កាន់តែល្អ។ ថែមរុក្ខជាតិបៃតង ដើម្បីសម្រួលការប៉ះទង្គិចជាមពលមមីនិងជូត។
- កត្តាមនុស្ស៖ ប្រើទិសនេះពេលមានការចាំបាច់សម្រេចលើកិច្ចការពាក់ព័ន្ធនឹងឥទ្ធិពលប្រចាំឆ្នាំខាងលើ ព្រោះជាទិសធុងប្រចាំឆ្នាំ។
- ហាម៖ វត្ថុមានចលនា ដំស្ងាន រុះរើ ជួសជុល សម្លេងខ្លាំងៗ ជីកគាស់..។
- ដាក់ឃ្លោកកាត់មាត់ចំហរ និងក្រឡអំបិលដើម្បីបន្ថយឥទ្ធិពលអាក្រក់។

METAFENIX ថៅ្ទាហ៊ីងស៊្វ

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

# 7

## ផ្កាយលេខ៧ ធាតុមាស ចូលទិសខាងត្បូងឆៀងលិច

- ទិសខាងត្បូងឆៀងលិច អង្សារ ២០២.៦ ដល់ ២៤៧.៥
- ធាតុប្រចាំទិស៖ ដី
- ឥទ្ធិពលប្រចាំឆ្នាំ៖ អាចមានឱកាសចំណេញលុយកាក់ តែក៏ប្រឈមខ្ពស់លើការប្រកួតប្រជែង ដណ្តើមប្រយោជន៍ ចោរកម្ម និងខាតបង់ទ្រព្យ។ ទិសនេះក៏នឹងបង្ករអារម្មណ៍ឯកោ មិនស្កប់ស្កល់ និងបញ្ហាសុខភាព( ទល់ខ្យល់ )។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ អ្នកមានផ្កាយជីវិតលេខ២ ស្រីវ័យចំណាស់ក្នុងគ្រួសារ និងអ្នកមានតួមមែ និងវកក្នុងតារាងរាសី។
- ការណែនាំ៖ ដាក់ទឹកចំណុះចាប់ពី៥លីត្រឡើង តែមិនត្រូវមានចលនាឡើយ។
- កត្តាមនុស្ស៖ ប្រើទិសនេះពេលមានការចាំបាច់ប៉ុណ្ណោះ។
- ហាម៖ វត្ថុមានចលនា ដំស្វាន រុះរើ ជួសជុល សម្លេងខ្លាំងៗ ជីកគាស់..។
- ដាក់ឃ្លោកកាត់មាត់ចំហរ និងក្រឡអំបិលដើម្បីបន្ថយឥទ្ធិពលអាក្រក់។

METAFENIX ពេញចិត្តហ៊ីនិង

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

8

# ផ្កាយលេខ៨ ធាតុដី ចូលទិសខាងកើត

- ទិសខាងកើត អង្សារ ៦៧.៦ ដល់ ១១២.៥
- ធាតុប្រចាំទិស៖ ឈើ
- ឥទ្ធិពលប្រចាំឆ្នាំ៖ សុខភាព ទ្រព្យធន ភាពរីកចម្រើន ល្បីល្បាញ និងជោគជ័យ តែបើមានថាមពលមិនល្អពីបរិស្ថានជុំវិញ វានឹងនាំអោយមានគ្រោះថ្នាក់ដល់ក្មេងតូចៗ។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ អ្នកមានផ្កាយជីវិតលេខ៣ មនុស្សប្រុសអាយុច្រើនក្នុងគ្រួសារ និងអ្នកមានតួឋោះក្នុងតារាងរាសី។
- ការណែនាំ៖ គោមអំបិល គ្រឿងបរិក្ខាអគ្គិសនី និងសម្ភារៈសាងពីដី/ព័រសីឡេន..។
- កត្តាមនុស្ស៖ ប្រើទិសនេះអោយបានច្រើន ដើម្បីទទួលឥទ្ធិពលពីផ្កាយ។

| | | |
|---|---|---|
| 9 | 5 | 7 |
| 8 | 1 | 3 |
| 4 | 6 | 2 |

# 9

## ផ្កាយលេខ៩ ធាតុភ្លើង ចូលទិសខាងត្បូងឆៀងកើត

- ទិសខាងត្បូងឆៀងកើត អង្សារ ១១២.៦ ដល់ ១៥៧.៥
- ធាតុប្រចាំទិស៖ ឈើ
- ឥទ្ធិពលប្រចាំឆ្នាំ៖ ជាផ្កាយល្អបំផុតប្រចាំយុគសម័យកាលទី៩ ដែលនាំអោយកើតមានទ្រព្យសម្បត្តិ ការវិនិយោគ ប្រជាប្រិយ៍ភាព សតិបញ្ញា ឡើងតំណែង..។
- អ្នកទទួលឥទ្ធិពលខ្លាំង៖ អ្នកមានផ្កាយជីវិតលេខ៤ មនុស្សស្រីអាយុច្រើនក្នុងគ្រួសារ និងអ្នកមានតួរោង និងម្សាញ់ក្នុងតារាងរាសី។
- ការណែនាំ៖ ដាក់តាំងគោមអំបិល គ្រឿងបរិក្ខាអគ្គិសនី ទឹកធ្លាក់មានភ្លើងលម្អ..។
- កត្តាមនុស្ស៖ ប្រើទិសនេះអោយបានច្រើន ដើម្បីទទួលឥទ្ធិពលពីផ្កាយ។

# តំបន់ភូមិសាស្ត្រ

METAFENIX



METAFENIX



METAFENIX





METAFENIX
2
6
4
3
1
8
7
5
9
N1
N2
N3
NE1
NE2
NE3
E1
E2
E3
SE1
SE2
SE3
S1
S2
S3
SW1
SW2
SW3
W1
W2
W3
NW1
NW2
NW3
壬 Ren
子 Zi
癸 Gui
丑 Chou
艮 Gen
寅 Yin
甲 Jia
卯 Mao
乙 Yi
辰 Chen
巽 Xun
巳 Si
丙 Bing
午 Wu
丁 Ding
未 Wei
坤 Kun
申 Shen
庚 Geng
酉 You
辛 Xin
戌 Xu
乾 Qian
亥 Hai

# កត្តាតារារាសី

METAFENIX
មេត្តាហ្វីនិច

# ភ្លើងយ៉ាង លើ មមី

អំណាច មន្តស្នេហ៍ ហ្មត់ចត់ ស្វែងរកភាពឥតខ្ចោះ ឱហាត រហ័សរហួន ក្លាហាន ផ្សងព្រេង ឯករាជ

រឹងរូស ងាយប៉ះទង្គិចអារម្មណ៍-មួរម៉ៅ បារម្ភច្រើន សម្ភារៈនិយម ឆាប់ធុញទ្រាន់ មិនសូវអត់ធ្មត់ មិនសូវគោរពច្បាប់ទម្លាប់ ចរិកមេ ជិះជាន់

| រាសី | ម៉ោង | ថ្ងៃ | ខែ | ឆ្នាំ |
| --- | --- | --- | --- | --- |
| រាសីមេឃ | កូនចៅ | សាម៉ីខ្លួន | មាតាបិតា | ចាស់ទុំ ថ្នាក់លើ |
| រាសីដី | ការវិនិយោគ | ប្ដី/ប្រពន្ធ | ការងារ | មិត្ត សង្គម |

METAFENIX ទេវតាហ៊ឺនិច្ច

# ជូត

ឆុងធំប្រចាំឆ្នាំ

- ចំនុចអវិជ្ជមាន៖ អាចមានការឈ្លោះប្រកែក របួសស្នាម ការនិយាយដើម/បរិហារ គ្រោះថ្នាក់ ជម្ងឺ ការខាតបង់ប្រាក់កាស កិច្ចការនានាពិបាកនឹងរីកចម្រើនទៅមុខ ងាយនឹងគេល្បួង អាចនឹងប្រឈមបញ្ហាផ្លូវច្បាប់ វិបត្តិផ្លូវចិត្ត ជាដើម។

- ចំនុចវិជ្ជមាន៖ សម្បូរឱកាសពីបុគ្គលដែលមានឋានៈខ្ពង់ខ្ពស់ ការបន់ស្រន់អាចនឹងទទួលផល តែគ្រប់យ៉ាងត្រូវរក្សាការប្រុងប្រយ័ត្នខ្ពស់។

- អ្នកដែលមានទឹកយ៉ាង ឬមាសយ៉ាង លើជូតក្នុងតារាងរាសី ហើយមិនត្រូវការធាតុភ្លើង នឹងជួបគ្រោះធំ។ គប្បីធ្វើកិច្ចកាត់គ្រោះ/កាត់ឆុង។
- ហាមចូលរួមបុណ្យសព ទៅសួរសុខទុក្ខអ្នកជម្ងឺនៅមន្ទីរពេទ្យ ឬទៅកន្លែងបញ្ចុះសព។

អ្នកជួយជ្រោមជ្រែង៖
ឆ្លូវ នឹងរោង

METAFENIX ពេទ្យាហ្វីនិច្ច

# ឆ្លូវ

ឆុងតូចប្រចាំឆ្នាំ

- ចំនុចអវិជ្ជមាន៖ ជួបឧបសគ្គច្រើន មានគេច្រណែន/ក្បត់ ប្រឈមគ្រោះធម្មជាតិ និងអាចមានសមាជិកក្នុងក្រុមគ្រួសារធ្លាក់ខ្លួនឈឺ។

- ចំនុចវិជ្ជមាន៖ ទទួលពរជ័យពីទេវតា មានកេរ្តិ៍ឈ្មោះល្អ និងមានគេជួយជ្រោមជ្រែង មានសមត្ថភាពក្នុងដោះស្រាយបញ្ហា បង្វែររឿងមិនល្អទៅជារឿងល្អ ទទួលឱកាសឡើងតំណែង និងប្រាក់ខែ។

- គប្បីធ្វើកិច្ចកាត់គ្រោះ/កាត់ឆុង ពិសេសអ្នកដែលមិនត្រូវការធាតុភ្លើង។
- ហាមចូលរួមបុណ្យសព ទៅសួរសុខទុក្ខអ្នកជម្ងឺនៅមន្ទីរពេទ្យ ឬទៅកន្លែងបញ្ចុះសព។

អ្នកជួយជ្រោមជ្រែង៖
វកា និងកុរ

METAFENIX ពេទ្យាហ៊ីនិច្ច

# ខាល

- ចំនុចអវិជ្ជមាន៖ អាចនឹងមានការបែកធ្លាយរឿងអាស្រូវស្នេហា អាចមានសមាជិកក្នុងគ្រួសារធ្លាក់ខ្លួនឈឺ ប្រឈមគ្រោះពីធម្មជាតិ ឬមានរបស់អ្វីមួយធ្លាក់ត្រូវបង្កររបួសស្នាម ជួបអំពើចោរកម្ម។

- ចំនុចវិជ្ជមាន៖ មានប្រជាប្រិយ៍ភាព សម្បូរមន្តស្នេហ៍ អ្នកនៅលីវអាចមានឱកាសជួបគូ អាចនឹងមានការធ្វើដំណើរច្រើន។

អ្នកជួយជ្រោមជ្រែង៖
ឋោះ និងកុរ

# ថោះ

ឆុងតូចប្រចាំឆ្នាំ

អ្នកជួយជ្រោមជ្រែង៖
មមែ និងកុរ

- ចំនុចអវិជ្ជមាន៖ អាចមានរឿងអាស្រូវស្នេហា ជម្លោះ ប្រឈមបញ្ហាផ្លូវច្បាប់ និងសម្ពាធផ្លូវចិត្ត។

- ចំនុចវិជ្ជមាន៖ ទទួលពរជ័យពីទេវតា មានឱកាសល្អច្រើនក្នុងរឿងលុយកាក់ មានលាភពីជីធ្លី មានប្រជាប្រិយ៍ភាព មានការជួយជ្រោមជ្រែងពីអ្នកមានឋានៈយសស័ក្តិក្នុងសង្គម សម្បូរសប្បាយ។

- គប្បីធ្វើកិច្ចកាត់គ្រោះ/កាត់ឆុង ពិសេសអ្នកដែលមិនត្រូវការធាតុភ្លើង។
- ហាមចូលរួមបុណ្យសព ទៅសួរសុខទុក្ខអ្នកជម្ងឺនៅមន្ទីរពេទ្យ ឬទៅកន្លែងបញ្ចុះសព។

METAFENIX ពេទ្យាហ៊ីនិច្ច

# រោង

- ចំនុចអវិជ្ជមាន៖ អាចមានរបួសហូរឈាម រោគឆ្លង ទទួលដំណឹងអកុសលពីសាច់ញាតិឬមិត្តភ័ក្រ្ត អស្ថេរភាពក្នុងជីវិត មានការខាតបង់ទ្រព្យធន សម្ពាធផ្លូវចិត្ត ឯកោ និងរបួសដែលនាំអោយមានសម្លាក។

- ចំនុចវិជ្ជមាន៖ មានភាពល្បីល្បាញ មានសមត្ថភាពដោះស្រាយបញ្ហា និងសម្បូរគេជួយ។

អ្នកជួយជ្រោមជ្រែង៖
វកា

METAFENIX ពេទ្យាហ្វីនិច្ច

# ម្សាញ់

- ចំនុចអវិជ្ជមាន៖ សម្ពាធក្នុងគ្រួសារនិងមុខរបររកស៊ី អាចឈានដល់ការឈ្លោះបែកបាក់ ប្រឈមបញ្ហាផ្លូវច្បាប់ សម្បូរឧបសគ្គ សុខភាពទ្រុឌទ្រោមបង្ករជាជម្ងឺ។
- ចំនុចវិជ្ជមាន៖ មានទ្រព្យធន សម្បូរសប្បាយមានហូបចុកគ្រប់គ្រាន់ ល្បីល្បាញ។

អ្នកជួយជ្រោមជ្រែង៖
ឆ្លូវ និងរកា

METAFENIX ហោរាហ្វីនិច្ច

# មមី

ឆ្នាំតូចប្រចាំឆ្នាំ

- ចំនុចអវិជ្ជមាន៖ ដាន់ឆ្នាំ ប្រឈមជម្ងឺ បញ្ហាផ្លូវច្បាប់បណ្តាលមកពីការទំនាក់ទំនងមិនយល់គ្នា ការក្បត់ពីក្រោយខ្នង ឬការមិនគោរពអោយតម្លៃ។

- ចំនុចវិជ្ជមាន៖ ក្លាហាន មានសមត្ថភាពដឹកនាំ មានយុទ្ធសាស្រ្ត មានឱកាសទទួលបានប្រាក់ចំណេញពីកិច្ចការរកស៊ី មានឆន្ទៈខ្ពស់ក្នុងការតទល់នឹងអ្នកមានអំណាចនិងជួយអ្នកទន់ខ្សោយ។

- គប្បីធ្វើកិច្ចកាត់គ្រោះ/កាត់ឆុង ពិសេសអ្នកដែលមិនត្រូវការជាតុភ្លើង។
- ហាមចូលរួមបុណ្យសព ទៅសួរសុខទុក្ខអ្នកជម្ងឺនៅមន្ទីរពេទ្យ ឬទៅកន្លែងបញ្ចុះសព។

អ្នកជួយជ្រោមជ្រែង៖ មមែ

# មមែ

- ចំនុចអវិជ្ជមាន៖ មហិច្ឆិតាធំហួសប្រមាណ ទទួលរងការប្រមាថ សងសឹក ប្រណែន និងសម្ពាធផ្លូវចិត្ត។
- ចំនុចវិជ្ជមាន៖ មានលាភពីប្តី/ប្រពន្ធ ឬបើអ្នកនៅលីវនឹងជួបគូដែលមកពីត្រកូលអ្នកធូរធារ ទទួលពរជ័យពីទេវតា មានឱកាសទទួលបានការងារល្អ/ឡើងតំណែង មានកេរ្តិ៍ឈ្មោះល្អ និងសម្បូរអ្នកជួយជ្រោមជ្រែង។

អ្នកជួយជ្រោមជ្រែង៖
ឆ្លូវ និងកុរ

METAFENIX ពេត្តាហ្វីនិច្ច

# វក

អ្នកជួយជ្រោមជ្រែង៖
រោង និងរកា

- ចំនុចអវិជ្ជមាន៖ អាចមានការកាន់ទុក្ខពីការបាត់បង់សមាជិកគ្រួសារ សាច់ញាតិ ឬមិត្តភ័ក្ត្រ ប្រឈមនឹងជួបជម្លោះតូចរីកទៅកាន់តែធំ ឬការកាច់កុងនៅកន្លែងធ្វើការជាដើម ទទួលអារម្មណ៍ឯកោ។

- ចំនុចវិជ្ជមាន៖ ឆាប់យល់ ចេះ ចាំ និងប្រើការបាន។ សម្បូរគំនិត និងទេពកោសល្យក្នុងការច្នៃប្រឌិត វិភាគ និងរៀបចំផែនការបានល្អ។ ឱកាសធ្វើដំណើរ ឬការប្តូរកន្លែងការងារ ប្តូរទីលំនៅ ចំណាកស្រុក ជាដើម។

- ហាមចូលរួមបុណ្យសព ទៅសួរសុខទុក្ខអ្នកជម្ងឺនៅមន្ទីរពេទ្យ ឬទៅកន្លែងបញ្ចុះសព។

មេធ្លាហ៊ីនិថ្ន

# វកា

- ចំនុចអវិជ្ជមាន៖ ប្រឈមគ្រោះថ្នាក់របួសស្នាម ធ្វើកិច្ចការអ្វីមិនសូវរលូនល្អ ដូចការគ្រោងទុក អាចមានការខាតបង់ប្រាក់កាស មានក្តីបារម្ភលើអស្ថេរភាពសេដ្ឋកិច្ចនិងសង្គម។

- ចំនុចវិជ្ជមាន៖ សម្បូរការជួយជ្រោមជ្រែង មានឱកាសស្គាល់អ្នកមានឋានៈខ្ពង់ខ្ពស់ សម្បូរលាភ សម្បូរប្រជាប្រិយ៍ បើអ្នកនៅលីវនឹងមានឱកាសជួបស្នេហ៍ បើអ្នកដែលមានគូរហើយនឹងកាន់តែសុខសាន្ត សុខភាពផ្លូវកាយនិងផ្លូវចិត្តមានលក្ខណៈស្ថិតស្ថេរល្អ។

អ្នកជួយជ្រោមជ្រែង៖
រោង និងឆ្លូវ

METAFENIX មេត្តាហ្វីនិច្ច

# ប

- ចំនុចអវិជ្ជមាន៖ ប្រឈមជម្លោះ និងការដោះស្រាយវិវាទផ្លូវច្បាប់ ការផាកពិន័យ ជម្ងឺឈឺថ្កាត់ និងសម្ពាធផ្លូវចិត្ត ។

- ចំនុចវិជ្ជមាន៖ ទទួលពរជ័យពីទេវតា មានអ្នកជួយជ្រោមជ្រែងចេញមុខជួយដោះស្រាយបញ្ហា។ មានគំនិតច្នៃប្រឌិត វិភាគ និងទេពកោសល្យល្អ ដែលអាចជួយអោយមានកេរ្តិ៍ឈ្មោះល្បាញល្បី និងអាចឡើងតំណែងទៀតផង។

អ្នកជួយជ្រោមជ្រែង៖ ជោះ

METAFENIX ទេវតាហ៊ីនិច្ច

# កុរ

- ចំនុចអវិជ្ជមាន៖ ប្រឈមស្ថានភាព ឬត្រូវចំណាយច្រើនបន្ទាន់ភ្លាមៗ ចោរកម្ម ចាញ់បោកប្រាក់កាស ឬខាតបង់លើការវិនិយោគ។
- ចំនុចវិជ្ជមាន៖ សម្បូរគេជួយយកអាសារលើកិច្ចការផ្សេងៗ និងសម្បូរលាភ។

អ្នកជួយជ្រោមជ្រែង៖
ជោះ និងមមែ

METAFENIX

ក្នុងឆ្នាំ២០២៦នេះ

អ្នកដែលមិនត្រូវការធាតុភ្លើងគួរប្រុងប្រយ័ត្នអោយបានខ្ពស់

ដូចអ្នកឆ្មុងដែរ

METAFENIX

កត្តាផ្លាស់ប្តូររាសី ប្រៀបដូចជា ការផ្លាស់ប្តូររដូវកាល

យើងមិនអាចឃាត់មិនអោយភ្លៀងនៅរដូវភ្លៀងឡើយ

METAFENIX

តែយើងអាច

រៀបចំខ្លួនឯងដោយត្រៀមលក្ខណៈមុនរដូវភ្លៀងមកដល់

METAFENIX មេតាហ្វីនិច្ច

មិនខ្វល់ថា រាសីល្អ ឬមិនល្អយ៉ាងនោះទេ

បើយើងគ្មានមានផែនការជីវិតច្បាស់លាស់ទេ

METAFENIX
មេតាហ្វីនិច

ជីវិតរបស់យើងនឹងដូចចកអណ្តែតនៅតាមខ្សែទឹកគ្មានកោះត្រើយដូចគ្នា

METAFENIX មេត្តាហ្វីនិច្ស

តែបើយើងមានផែនការជីវិត និងយុទ្ធសាស្ត្រច្បាស់លាស់

យើងនឹងអាចគ្រប់គ្រងស្ថានការណ៍បានល្អ

ពេលនោះ គ្រោះ អាចក្លាយទៅជា លាភ

កម្លាំងស្មារតី កម្លាំងកាយ និងកម្លាំងចិត្ត

ត្រូវដើរទន្ទឹមគ្នា

ក្រោកឈរឡើង រៀបចំជីវិតជាមួយក្តីសង្ឃឹម
ក្រុមគ្រួសារ និងជាតិមាតុភូមិកំពុងត្រូវការយើង!

យើងក៏មិនត្រូវភ្លេចឡើយនូវ



ហុងស៊ុយចិត្តគំនិត



ហុងស៊ុយរាងកាយ



ហុងស៊ុយបរិស្ថាន

METAFENIX មេត្តាហ្វីនិច្ច

ចូរបង្កើតឆ្នាំ២០២៦ ជាជំពូកប្រវត្តិសាស្ត្រថ្មី ក្នុងជីវិតរបស់អ្នក
អោយមានន័យជាងវេលាកន្លងទៅ!

## បរិបទថ្មីនៃការប្រឹក្សាជីវិត

ទទួលបានវិញ្ញាបនបត្រជា អ្នកប្រឹក្សាជីវិតប្រកបដោយវិជ្ជាជីវៈ
( CERTIFIED PROFESSIONAL LIFE COACH )
ពីវិទ្យាស្ថាន TRANSFORMING ACADEMY នៅសហរដ្ឋអាមេរិក

METAFENIX



1 6 8
9 2 4
5 7 3
S1 S2 S3
SW1 SW2 SW3
W1 W2 W3
NW1 NW2 NW3
N1 N2 N3
NE1 NE2 NE3
E1 E2 E3
SE1 SE2 SE3
丙 Bing
午 Wu
丁 Ding
未 Wei
坤 Kun
申 Shen
庚 Geng
酉 You
辛 Xin
戌 Xu
乾 Qian
亥 Hai
壬 Ren
子 Zi
癸 Gui
丑 Chou
艮 Gen
寅 Yin
甲 Jia
卯 Mao
乙 Yi
辰 Chen
巽 Xun
巳 Si